ក្រសួងមហាផ្ទៃ Ministry of Interior

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
General Department of Identification

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

**ឧត្តមសេនីយ៍ទោ អ៊ុកចាយ បញ្ញារ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
(855)12547788 – (855)16547788

បុគ្គលគ្រប់រូបត្រូវបានកំណត់អត្តសញ្ញាណ - Everyone is identified

# ១. សេចក្តីផ្តើម

ការងារអត្តសញ្ញាណកម្មផ្តោតលើការងារចម្បងពីរគឺ ការគ្រប់គ្រងអត្តសញ្ញាណប្រជាពលរដ្ឋ និងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ។

- **ការងារគ្រប់គ្រងប្រជាពលរដ្ឋ៖** គឺជាឆ្អឹងខ្នងនៃការគ្រប់គ្រងរដ្ឋបាលដែនដី ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ធានានូវសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់ជាមូលដ្ឋានរបស់បុគ្គល និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- **ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ៖** សំដៅដល់ការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល ដើម្បីផ្តល់សេវានានាជូនប្រជាពលរដ្ឋ ដូចជាការផ្តល់សំបុត្រកំណើត អត្តសញ្ញាណបណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ លិខិតឆ្លងដែនជាដើម។

# ១. សេចក្តីផ្តើម(ត)

**ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម (ផ.យ.ជ.អ)**៖មានគោលបំណងសម្រេចចក្ខុវិស័យរយៈពេលវែងសម្រាប់ព្រះរាជាណាចក្រកម្ពុជា គឺមនុស្សគ្រប់រូបត្រូវមានអត្តសញ្ញាណច្បាស់លាស់។ ការងារនេះនឹងទាមទារឲ្យមានការកសាង៖

- ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានទំនើប មានលក្ខណៈជាសកល
- ប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន(ប.រ.អ.ប)

- ❑ បុគ្គលម្នាក់ៗនឹងត្រូវផ្តល់ឲ្យនូវលេខកូដអត្តសញ្ញាណខ្មែរ(Khmer ID Code-KIDC) ផ្ទាល់ខ្លួនមួយនៅពេលដែលពួកគេចុះបញ្ជីកំណើត ហើយនឹងបន្តប្រើប្រាស់ពេញមួយជីវិតរបស់ពួកគេ។

# ២. ចក្ខុវិស័យ

ចក្ខុវិស័យលើការងារអត្តសញ្ញាណកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺ៖

*"ការផ្តោតលើបេសកកម្មជាអាទិភាព ការតម្រង់ទិសទៅរកការផ្តល់សេវាកម្មល្អ និងការធ្វើទំនើបកម្មលើវិស័យរដ្ឋបាលសាធារណៈ ដែលអាចគ្រប់គ្រងបាននូវទិន្នន័យអត្តសញ្ញាណប្រជាជន ទិន្នន័យព្រឹត្តិការណ៍ជីវិត និងផលិតបាននូវស្ថិតិប្រជាជននិងស្ថិតិអត្រានុកូលដ្ឋានប្រកបដោយភាពជឿទុកចិត្ត"*

# ៣. បេសកកម្ម

បេសកកម្មនៃលើការងារអត្តសញ្ញាណកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺ៖

*"ការចុះបញ្ជីប្រជាជនគ្រប់រូបនិងព្រឹត្តិការណ៍ជីវិតតាមវិធីប្រកបដោយប្រសិទ្ធភាព គុណភាព និងមិនមានភាពរើសអើង ដើម្បីផ្តល់នូវកេស្តុតាងអត្តសញ្ញាណផ្លូវច្បាប់សម្រាប់ជានាឱ្យមានសិទ្ធិស្មើគ្នានៅក្នុងសង្គម សម្រាប់ផ្តល់នូវទិន្នន័យដែលជឿទុកចិត្តនិងមានសុវត្ថិភាព ជួយដល់អភិបាលកិច្ចល្អ និងសម្រាប់ចូលរួមដល់ការអភិវឌ្ឍវិស័យឯកជននិងវិស័យសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា"*

# ៤. គោលបំណង និងគោលដៅ

*"កសាងនូវប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណកម្មតែមួយសម្រាប់បម្រើឲ្យសកម្មភាព ផ្តល់សេវាសាធារណៈ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ វិស័យយុត្តិធម៌ និងវិស័យឯកជនដទៃទៀតដើម្បីឆ្លើយតបទៅនឹងគោលនយោបាយខាងលើ"*

# ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

- ទិសដៅជាយុទ្ធសាស្ត្រ



# ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ(ត)

## - គោលបំណងយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រទី១៖ ការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណ

យុទ្ធសាស្ត្រទី២៖ បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតប

យុទ្ធសាស្ត្រទី៣៖ បង្កើតប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

យុទ្ធសាស្ត្រទី៤៖ ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យប្រជាជន

យុទ្ធសាស្ត្រទី៥៖ កែសម្រួលរបៀបរបបការងារនិងដាក់ឱ្យដំណើរការប្រព័ន្ធអេឡិចត្រូនិកសម្រាប់ផ្តល់សេវាជូនប្រជាជនប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព

- គោលដៅ គឺជាអ្វីដែលអាចវាស់វែងបាននិងមានគុណតម្លៃទៅតាមក្របខ័ណ្ឌពេលវេលាជាក់លាក់ ដែលអាចជួយឱ្យសម្រួលបាននូវគោលបំណងយុទ្ធសាស្ត្ររួម។

# គោលបំណងយុទ្ធសាស្រ្តទី១៖ រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណបុគ្គល

គោលបំណងយុទ្ធសាស្រ្តនេះ គឺការធ្វើអោយបរិយាកាសផ្នែកច្បាប់ដែលមានអំណោយផលថ្មីសម្រាប់វិស័យនេះ តាមរយៈការបង្កើតក្របខ័ណ្ឌច្បាប់ដែលចាំបាច់សម្រាប់រៀបចំមូលដ្ឋានគ្រឹះនៃប្រព័នអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានទំនើប ដើម្បីបម្រើតម្រូវការរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រជាជនរបស់ខ្លួន។ កិច្ចការនេះនឹងជួយសម្រួលដល់ប្រតិបត្តិការរបស់ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនផងដែរ។

- គោលដៅទី១៖ សេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ខែមិនា ឆ្នាំ២០២២នេះ)
- គោលដៅទី២៖ អនុក្រឹត្យស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល (ខែធ្នូ ឆ្នាំ២០២១)

# គោលបំណងយុទ្ធសាស្ត្រទី២៖

បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដោយផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) មានលក្ខណៈជាសកល និងមានការឆ្លើយតប

| គោលដៅទី១ | គោលដៅទី២ | គោលដៅទី៣ | គោលដៅទី៤ |
| --- | --- | --- | --- |
| បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈសកលដោយប្រើប្រព័ន្ធប.គ.ព | បង្កើតប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន | ភ្ជាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននិងប្រព័ន្ធជំនួយផ្សេងទៀតសម្រាប់ការផ្លាស់ប្តូរ ទិន្នន័យ | បង្កើនការគ្របដណ្តប់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន |

# ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន CRVS system




ទស្សនាទាននៃការរៀបចំប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា

# គោលបំណងយុទ្ធសាស្ត្រទី៣៖ ការបង្កើតប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

| គោលដៅទី១ | គោលដៅទី២ | គោលដៅទី៣ | គោលដៅទី៤ | គោលដៅទី៥ | គោលដៅទី៦ | គោលដៅទី៧ |
|---|---|---|---|---|---|---|
| បង្កើតមជ្ឈមណ្ឌលទំនើបនិងមានសុវត្ថិភាពសម្រាប់ ប.វ.អ.ប | បង្កើតឱ្យមានលេខកូដអត្តសញ្ញាណខ្មែរដល់ប្រជាជនទាំងអស់ដែលបានកំណត់អត្តសញ្ញាណរួច | បង្កើតបញ្ជីប្រជាជន | បង្កើតប្រព័ន្ធគ្រប់គ្រងកាស្នាក់នៅទំនើបនិងភ្ជាប់ជាមួយនិង ប.វ.អ.ប | បង្កើតប្រព័ន្ធគ្រប់គ្រងសញ្ជាតិដែលមានប្រសិទ្ធិភាពនិងភ្ជាប់ជាមួយ ប.វ.អ.ប | ធ្វើទំនើបកម្មនិងភ្ជាប់ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាមួយនិង ប.វ.អ.ប | ធ្វើទំនើបកម្មនិងភ្ជាប់ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែនជាមួយនិង ប.វ.អ.ប |

# ប្រព័ន្ធអត្តសញ្ញាណកម្មប្រជាជន ប.រ.អ.ប




ទស្សនាទាននៃការរៀបចំប្រព័ន្ធរួមអត្តសញ្ញាណប្រជាជននៃព្រះរាជាណាចក្រកម្ពុជា

# គោលបំណងយុទ្ធសាស្ត្រទី៤៖ ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យប្រជាជន

## គោលដៅទី ១

បង្កើតប្រព័ន្ធបែងចែកទិន្នន័យ

## គោលដៅទី ២

បំពេញតាមសំណូមពរស្នើសុំព័ត៌មានឱ្យបានពី២លានដងក្នុង១ឆ្នាំ
២០២៦

# គោលបំណងយុទ្ធសាស្ត្រទី៥៖

## កែសម្រួលរបៀបរបបការងារនិងដាក់ឱ្យដំណើរការប្រព័ន្ធអេឡិចត្រូនិកសម្រាប់ផ្តល់សេវាជូនប្រជាជនប្រកបដោយប្រសិទ្ធិភាពនិងតម្លាភាព

### គោលដៅទី១

ជំរុញឱ្យមានការចូលរួមរបស់ពលរដ្ឋ

### គោលដៅទី២

កែសម្រួលរបៀបរបបការងារសម្រាប់លើកកម្ពស់ការផ្តល់សេវាកម្ម

### គោលដៅទី៣

ណែនាំឱ្យប្រើប្រាស់សេវាកម្មប្រព័ន្ធអេឡិចត្រូនិក

# សូមអរគុណ!